00407268

លេខ/N: D242/3

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 02 / 12 / 2009
ម៉ោង (Time/Heure): 11:35
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

# ការិយាល័យសហចៅក្រមស៊ើបអង្កេត
# OFFICE OF THE CO-INVESTIGATING JUDGES
# BUREAU DES CO-JUGES D'INSTRUCTION

ជូនចំពោះ៖ **សហព្រះរាជអាជ្ញា** កាលបរិច្ឆេទ៖ ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៩

លោកស្រី ជា លាង

លោក William SMITH

**Declassified to Public**

**12 April 2013**

ពី៖ **ចៅក្រម យូ ប៊ុនឡេង**

**Marcel LEMONDE**

**សហចៅក្រមស៊ើបអង្កេត**

## សម្គាត់

កម្មវត្ថុ៖ **សំណើរបស់លោក លោកស្រី សុំឲ្យបំពេញកិច្ចស៊ើបសួរទាក់ទិននឹងមជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam)**

យោង៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស

ក្នុងសំណើរបស់លោក លោកស្រី ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៩ លោក លោកស្រី បានស្នើឲ្យសហចៅក្រមស៊ើបអង្កេត ("ស.ច.ស") "*ស្នើសុំឲ្យ (DC-Cam) ជួយដល់សហចៅក្រមស៊ើបអង្កេតដោយធ្វើការពិនិត្យឡើងវិញនូវបណ្ណសាររបស់ពួកគេ ដើម្បីកំណត់អត្តសញ្ញាណនៃភស្តុតាងទាក់ទងនឹងកម្មវត្ថុនៃកិច្ចស៊ើបសួរនេះទៅតាមបញ្ជីដែលមានភ្ជាប់មកជាមួយ "ឧបសម្ព័ន្ធ៤" និងបញ្ជូនភស្តុតាងទាំងនោះមកសហចៅក្រមស៊ើបអង្កេតដើម្បីដាក់បញ្ចូលទៅក្នុងសំណុំរឿង*[1]"។ បន្ថែមពីលើសំណើនេះ

[1] D242 **សំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យបំពេញកិច្ចស៊ើបសួរទាក់ទិននឹងមជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam)** ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៩ កថាខណ្ឌ ១៤។

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 02 / 12 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

សហមេធាវីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ បានដាក់ចម្លើយតបមួយ[2]។ ស.ច.ស បានធ្វើការកត់សម្គាល់រួចហើយនូវមាតិកានៃសំណើរបស់ជនជាប់ចោទ។

សហចៅក្រមស៊ើបអង្កេតសូមជម្រាបសហព្រះរាជអាជ្ញាថា ការប្រមូល ការវិភាគ និងការពិនិត្យឡើងវិញនូវឯកសារពីបណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) គឺកំពុងបានបន្តធ្វើនៅគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចស៊ើបសួរ។ ការពិនិត្យបណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា គឺជា និងនៅតែបន្តជាធនធានដ៏មានតម្លៃមួយដល់កិច្ចស៊ើបសួរ។ ធនធានផ្នែកច្បាប់ និងផ្នែកវិភាគសំខាន់ៗនៅឯការិយាល័យសហចៅក្រមស៊ើបអង្កេត (ក.ស.ច.ស) ត្រូវបានប្រើប្រាស់ក្នុងការស្វែងរកភស្តុតាងពាក់ព័ន្ធនានា។

ក្នុងអំឡុងដំណើរការនេះ បណ្ណសារ DC-Cam ត្រូវបាន ក.ស.ច.ស ធ្វើការស្រាវជ្រាវរកឯកសារជាលក្ខណៈប្រព័ន្ធ ផ្អែកលើមូលដ្ឋានលក្ខណៈវិនិច្ឆ័យលម្អិតក្នុងការស្រាវជ្រាវឯកសារ ដែលត្រូវបានបង្កើតឡើងអនុលោមតាមរាល់ស្ថានភាពអង្គហេតុជាក់ស្តែងទាំងអស់ដែល ស.ច.ស ត្រូវបានប្តឹងក្នុងវិសាលភាពនៃកិច្ចស៊ើបសួរ និងតាមរយៈលក្ខណៈវិនិច្ឆ័យដែលជាអាទិភាព ដែលត្រូវបានបង្កើតឡើងតាមមូលដ្ឋាននៃប្រភេទឯកសារដែលចាត់ទុកថាពាក់ព័ន្ធបំផុត[3]។ យើងបានប្រមែប្រមូលភស្តុតាងពាក់ព័ន្ធទាំងអស់ដែលបានមកពីការស្រាវជ្រាវ ហើយនាពេលបច្ចុប្បន្ន ភស្តុតាងទាំងនេះស្ថិតក្នុងដំណើរការនៃការត្រួតពិនិត្យតាមទិដ្ឋភាពច្បាប់។ ក្នុងការត្រួតពិនិត្យឯកសារទាំងនេះ ស.ច.ស បានយកកម្មវត្ថុនៃកិច្ចស៊ើបសួរមកធ្វើការពិចារណា និងពិនិត្យមើលថាតើភស្តុតាងនេះអាចជាភស្តុតាងដាក់បន្ទុក ឬដោះបន្ទុក។

មកទល់ពេលនេះ ឯកសារក្នុងចំនួនជាង១.០០០ ត្រូវបានដកយកចេញពីបណ្ណសារ។ ឯកសារនីមួយៗមានចាប់ពីមួយទំព័រដល់ជាង១០០ទំព័រ។ ជារួម ក្រោយពីបានស្រាវជ្រាវឯកសារនៅបណ្ណសារDC-Cam ស.ច.ស បានដកយកចេញពីបណ្ណសារនូវឯកសារចំនួនជាង ៤.០០០ ទំព័រ សម្រាប់យកមកធ្វើ

---

[2] D242/2 **ចម្លើយតបរបស់មេធាវីការពារក្តីទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យបំពេញកិច្ចស៊ើបសួរទាក់ទិននឹងមជ្ឈមណ្ឌលឯកសារកម្ពុជា** ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩។

[3] ឧទាហរណ៍ នៅក្នុងចំណោមប្រការផ្សេងៗ ប្រភេទនៃការស្វែងរកឯកសាររួមមាន៖ កំណត់ហេតុកិច្ចប្រជុំបក្សកុម្មុនីស្តកម្ពុជា តេឡេក្រាម សេចក្តីណែនាំបក្សកុម្មុយនីស្តកម្ពុជា និងកំណត់ហេតុនៃការជីកគាស់កាយរណ្តៅសាកសពក្រោយឆ្នាំ១៩៧៩។

00407270



ការត្រួតពិនិត្យតាមទិដ្ឋភាពច្បាប់ ផ្អែកតាមលក្ខណៈវិនិច្ឆ័យក្នុងការស្រាវជ្រាវរបស់ពួកគេ[4]។ ស.ច.ស តែងតែខិតខំផ្តោតការយកចិត្តទុកដាក់ទៅលើតែឯកសារណាដែលពាក់ព័ន្ធផ្ទាល់ និងចាំបាច់ប៉ុណ្ណោះ ពោលគឺយើងមិនយកចិត្តទុកដាក់ទៅលើឯកសារណាដែលមិនពាក់ព័ន្ធ ឬច្រំដែលទេ។

បន្ថែមពីលើការស្រាវជ្រាវឯកសារខាងលើ ក្នុងពេលណាក៏ដោយឱ្យតែមានសញ្ញាសមស្របមួយ បង្ហាញថា DC-Cam មានឯកសារដែលរួមចំណែកដល់ការបញ្ជាក់ការពិតស្តីពីបញ្ហាមួយចំនួនពាក់ព័ន្ធនឹងកិច្ចស៊ើបសួរ ពេលនោះយើងនឹងបានទទួលឯកសារទាំងនោះ។ អនុលោមតាមដីកាចាត់ឱ្យស៊ើបសួរជំនួស ក.ស.ច.ស បានធ្វើដំណើរទៅកាន់ DC-Cam ជាច្រើនលើកដើម្បីទទួលយកឯកសារទាំងនេះបន្ថែមទៀតសម្រាប់ធ្វើការត្រួតពិនិត្យតាមទិដ្ឋភាពច្បាប់។

នាពេលបច្ចុប្បន្ន យើងកំពុងដាក់លទ្ធផលនៃការត្រួតពិនិត្យឯកសារតាមទិដ្ឋភាពច្បាប់ចូលទៅក្នុងសំណុំរឿង ពោលគឺឯកសារទាំងឡាយណាដែលបានបំពេញតាមលក្ខខណ្ឌដែលបានលើកឡើងពីខាងដើម នឹងត្រូវបានដាក់ចូលទៅក្នុងសំណុំរឿងលេខ២ ហើយប្រសិនបើចាំបាច់ យើងនឹងស្នើឱ្យគេបកប្រែឯកសារទាំងនោះ។ ទោះក្នុងកាលៈទេសៈណាក្តី ស.ច.ស សូមបញ្ជាក់ថាក្នុងដំណើរការនៃការត្រួតពិនិត្យឯកសារតាមទិដ្ឋភាពច្បាប់នេះនឹងត្រូវចប់ជាស្ថាពរនៅមុនពេលថ្ងៃបញ្ចប់នៃកិច្ចស៊ើបសួរ ហើយភស្តុតាងទាំងអស់ពីបណ្ណសារ DC-Cam ដែលយើងបានកំណត់ថាមានការពាក់ព័ន្ធដល់បញ្ជាក់ការពិត (មិនថាជាភស្តុតាងដោះបន្ទុក ឬដាក់បន្ទុក) នឹងត្រូវបានដាក់ចូលទៅក្នុងសំណុំរឿងលេខ២។ បន្ទាប់មកយើងនឹងជូនដំណឹងប្រាប់ភាគីតាមការគួរ[5]។ មាតិកាឯទៀតនៃឯកសារពុំពាក់ព័ន្ធដែលនៅសេសសល់ដែលយើងបានដកយកចេញពីបណ្ណសារ DC-Cam ដែលពុំចាំបាច់ដាក់ចូលទៅក្នុងសំណុំរឿង ប៉ុន្តែអាចជាឯកសារសំខាន់សម្រាប់មេធាវីការពារក្តី នឹងត្រូវដាក់នៅក្នុងឃ្លាំងផ្ទុកឯកសាររួម Shared Material Drive ដែលភាគីអាចចូលទៅពិនិត្យមើលបាន។

---

[4] គួរកត់សម្គាល់ថាឯកសារទាំងនេះភាគច្រើនជាភាសាខ្មែរ ដែលប៉ះពាល់ដល់ជំហាននៃការត្រួតពិនិត្យតាមទិដ្ឋភាពច្បាប់នៅ ក.ស.ច.ស។

[5] ប៉ុន្តែគួរបញ្ជាក់ថា ការវាយតម្លៃជាចុងក្រោយអំពីសារសំខាន់នៃការត្រួតពិនិត្យឯកសារតាមទិដ្ឋភាពច្បាប់ ពុំអាចចប់សព្វគ្រប់នៅមុនពេលបញ្ចប់កិច្ចស៊ើបសួរបានឡើយ។ ការកំណត់ជាស្ថាពររបស់ ស.ច.ស អំពីប្រភេទអង្គហេតុ និងអង្គច្បាប់នឹងមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។